**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**វិទ្យាស្ថានសន្តប៉ូល**
Saint Paul Institute

# ការណែនាំជាមូលដ្ឋានសម្រាប់
# ការសិក្សាពីចម្ងាយ និង ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក
**(Distance and E-Learning)**

ដើម្បីឱ្យការសិក្សាពីចម្ងាយ និង ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក (Distance and E-Learning) ប្រកបដោយក្រមសីលធម៌ និងមានដំណើរការទៅដោយជោគជ័យ វិទ្យាស្ថានសន្តប៉ូល តម្រូវឱ្យនិស្សិតទាំងអស់គោរពឱ្យបានខ្ជាប់ខ្ជួននូវការណែនាំដូចខាងក្រោម៖

**១. សម្រាប់និស្សិត**

១.១. និស្សិតត្រូវតែចូលរួមសិក្សាក្នុងម៉ោងបង្រៀន ការសិក្សាពីចម្ងាយ និង ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក (Distance and E-Learning) ក្នុងកម្មវិធី Zoom និង Google Classroom និងធ្វើការសន្ទនា(ចោទសំណួរ ឬ ផ្ដល់យោបល់)។ វត្តមាននិស្សិតក្នុងការចូលរួមសិក្សាក្នុងកម្មវិធី Zoom និង Google Classroom នឹងត្រូវដាក់ចូលក្នុងការវាយតម្លៃសម្រាប់ឆមាសទី២។

១.២. ក្នុងករណីនិស្សិតខកខានមិនបានចូលរួមសិក្សាក្នុងម៉ោងបង្រៀន ដោយបញ្ហាគ្មានសេវាអ៊ីនធឺណិត ឬ អគ្គិសនី។ល។ និស្សិតត្រូវតែចូលទៅមើលវីដេអូបង្រៀន ដែលបានថតទុកក្នុងម៉ោងបង្រៀន ហើយបើមានសំណួរ អាចចោទសួរទៅសាស្ត្រាចារ្យតាមការណែនាំនៃមេរៀននីមួយៗ។

១.៣. និស្សិតទាំងអស់ត្រូវប្រើប្រាស់សំណួរ ចម្លើយ យោបល់ ឬ ការសន្ទនាដែលទាក់ទងនឹងមេរៀនប៉ុណ្ណោះ ហើយត្រូវប្រកាន់ភ្ជាប់នូវក្រមសីលធម៌។

១.៤. និស្សិតទាំងអស់ត្រូវជៀសវាងការប្រើប្រាស់ពាក្យដែលមានអត្ថន័យប្រមាថ ឬ ប៉ះពាល់ចំពោះគ្នាទៅវិញទៅមក ចំពោះបុគ្គលផ្សេងៗ ចំពោះរាជរដ្ឋាភិបាល ជាពិសេសចំពោះព្រះចេស្ដាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។

១.៥. និស្សិតទាំងអស់**មិនអនុញ្ញាត**ឱ្យពិភាក្សា ឬ ធ្វើការសន្ទនាដែល**ទាក់ទងនឹងនយោបាយជាច់ខាត** នៅក្នុងថ្នាក់រៀន ការសិក្សាពីចម្ងាយ និង ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក (Distance and E-Learning)។

១.៦. ការលេងសើច ការសន្ទនាប្រកបដោយ**កំហឹង និងភាពអវិជ្ជមាន** ដែលធ្វើឱ្យប៉ះពាល់/រំខានដល់ការសិក្សាត្រូវបានហាមឃាត់។

១.៧. មិនត្រូវ**ថត ឬ កាត់**យកផ្នែកណាមួយនៃវីដេអូបង្រៀន ឯកសារ និងពាក្យសំដីនៅក្នុងថ្នាក់រៀន ធ្វើការ**ចែករំលែក**បន្តក្នុងបណ្ដាញសង្គម ឬ អ្នកដែលគ្មានការពាក់ព័ន្ធ។

១.៨. មិនត្រូវយក**រូបភាព ឬ វីដេអូ** នៃការបង្រៀនទៅ**ធ្វើជារូបកំប្លែង** ឬ ធ្វើឱ្យ**ប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូរ**របស់សាស្ត្រាចារ្យទេ។

១.៩. និស្សិតតម្រូវឱ្យ**ធ្វើលំហាត់ និងកិច្ចការ**ដែលសាស្ត្រាចារ្យបានដាក់ឱ្យធ្វើ ឱ្យរួចរាល់បន្ទាប់**ពីមេរៀននីមួយៗ ហើយត្រូវប្រគល់កិច្ចការដែលបានធ្វើហើយទៅសាស្ត្រាចារ្យ។ គ្រប់លំហាត់និងកិច្ចការទាំងអស់នឹងត្រូវដាក់ពិន្ទុសម្រាប់ឆមាសទី២។**

១.១០. និស្សិតទាំងអស់ត្រូវបានលើកទឹកចិត្តឱ្យជួយបង្រៀននិស្សិតដទៃទៀត។

១.១១. និស្សិតដែលមិនបានគោរពទៅតាមលក្ខខណ្ឌនេះ នឹងត្រូវទទួល**ពិន័យទៅតាមវិន័យរបស់វិទ្យាស្ថាន ឬ** ទទួលខុសត្រូវតាមច្បាប់ដោយបុគ្គលផ្ទាល់។

ថ្ងៃច័ន្ទ ១៣រោច ខែចេត្រ ឆ្នាំជូត ទោស័ក ពស ២៥៦៣

ត្រូវនឹងថ្ងៃទី២០ ខែមេសា ឆ្នាំ២០២០

**នាយកវិទ្យាស្ថាន**

ផុន_សុផល

**វិទ្យាស្ថានសន្តប៉ូល . ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ** ភូមិអង្គគគីរ ឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ (ខាងជើងផ្សារអង្គតាសោម)
SAINT PAUL INSTITUTE - THE APOSTOLIC VICARIATE OF PHNOM PENH ANGKORKI VILLAGE, TAPAM COMMUNE, TRAMKOK DISTRICT, TAKEO PROVINCE, CAMBODIA
Phone: (855-32) 63 90 003 E-mail: spi.takeo@gmail.com Website: www.spi.edu.kh Facebook: Saint Paul Institute